**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ១១ប្រ
ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៤
**សាលដីកា**
លេខៈ២១៥
ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ............ ជាចៅក្រម
៥-លោក ............. ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**
-លោក ...............

**តំណាងមហាអយ្យការ**
-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៥១ (ក) ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៤៩ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ មណរជាចុងបណ្តឹងសាទុក្ខ ភេទប្រុស អាអាយុ៥០ឆ្នាំ ជាតិខ្មែរ របររកស៊ីមន្ត្រីក្រសួងមហាផ្ទៃ មានទីលំនៅផ្ទះលេខ៣៥$E_0$ ផ្លូវលេខ២១៧ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ ឪពុកឈ្មោះម៉ឺ ភិរុណា (ស) ម្តាយឈ្មោះ អ៊ុក ថូ(ស) ។

និង ដើមចោទឈ្មោះនកណរ ជាចុងបណ្តឹងសាទុក្ខ ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ របររកស៊ីនគរបាលក្រសួងមហាផ្ទៃ មានទីលំនៅផ្ទះលេខ៥៦$E_0$ ផ្លូវលេខៈ៣២៤ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះនង គីនីន (ស) ម្តាយឈ្មោះម៉ែ កន្ទរី(ស) ។

និង ចុងចម្លើយឈ្មោះសសប ជាម្ចាស់បណ្តឹងសាទុក្ខ ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ របររកស៊ីសាស្ត្រចារ្យវិទ្យាស្ថានភាសាបរទេស មានទីលំនៅ ផ្ទះលេខ១$E_2$ ផ្លូវលេខ២៦១ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ ស៊ុម សេន(ស) ម្តាយឈ្មោះ សាយ ឡាក់(ស) ។

កម្មវត្ថុបណ្តឹងៈប្តឹងទាស់ដីកាសម្រេចកិច្ចការប្រញាប់លេខ២៤ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ។

បានឃើញបណ្តឹងសាទុក្ខលេខៈ២៩៧ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះសសប បានប្តឹង មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១១ប្រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៤ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១១-១០-២០០២ របស់ឈ្មោះសសប ប្ដឹងសុំដីកាចារលើពាក្យសុំហាមឃាត់មិនឲ្យឈ្មោះហេង ពន្លក និងឡុក គីម ធ្វើប័ណ្ណសំគាល់កម្មសិទ្ធិ មិនឱ្យលក់-ដូរ, ជួល បញ្ចាំ ឬធ្វើ អំណោយ និងមិនឱ្យសាងសង់សំណង់អ្វីមួយនៅលើដីឡូត៍លេខ១២២ ក្រុម៣០ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោកក្រុងភ្នំពេញជាបណ្ដោះអាសន្ន ។

តាមបណ្ដឹងទាស់ចុះថ្ងៃទី០៣-១២-២០០២ របស់ឈ្មោះឡុក គីម ប្ដឹងទាស់លើដីកាសម្រេចតាមពាក្យសុំលេខ២២(ឈ) ចុះថ្ងៃទី២៥-១១-២០០២ របស់តុលាការក្រុងភ្នំពេញ ដោយអាងហេតុថា៖តុលាការសម្រេច តាមពាក្យបណ្ដឹងចុះថ្ងៃទី១១-១០-២០០២ របស់ឈ្មោះសសប តាមអំណាចដីកា សម្រេចតាមពាក្យសុំលេខ២២(ឈ) ចុះថ្ងៃទី២៥-១១-២០០២ របស់តុលាការក្រុងភ្នំពេញ បានធ្វើឱ្យប៉ះពាល់ ផលប្រយោជន៍ របស់ខ្លួនយ៉ាងខ្លាំង ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ២២(ឈ) ចុះថ្ងៃ២៥-១១-២០០២ របស់តុលាការក្រុង ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី១១-១០-២០០២ របស់ដើមចោទឈ្មោះសសប ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ហាមឃាត់ឈ្មោះហេង ពន្លក និងឈ្មោះ ឡុក គីម ទីលំនៅបច្ចុប្បន្នផ្ទះលេខ១២២ ផ្លូវ២៦១ ក្រុមទី៣០ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ មិនឱ្យលក់ដូរ, ជួល បញ្ចាំ, ផ្ទេរសិទ្ធិ ធ្វើអំណោយ និងសាងសង់សំណង់អ្វី មួយនៅលើដីឡូត៍លេខ:១២២ ផ្លូវ២៦១ ក្រុមទី៣០ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទុកជាបណ្ដោះអាសន្ន រងចាំតុលាការសម្រេចដល់រឿងអង្គសេចក្ដីចប់ជាស្ថាពរ ។

៣- បង្គាប់ឱ្យឈ្មោះហេង ពន្លក និងឈ្មោះ ឡុក គីម បង់ប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង ចំនួន ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ សរុបចំនួន២.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ចំនួន ២.០០០៛ ដែលដើមចោទបានបង់ទុកជាស្រេច ។

៤ -ដីកាសម្រេចនេះមានអនុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្ដឹងឧទ្ធរណ៍ក៏ដោយ

៥ -បើគូភាគីណាមិនសុខចិត្តនឹងដីកាសម្រេចនេះ មានសិទ្ធិប្ដឹងទាស់រយៈពេល១៥ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹងពីដីកាសម្រេចនេះតទៅ ។

បានឃើញពាក្យបណ្ដឹងទាស់របស់ឈ្មោះឡុក គីម ចុះថ្ងៃទី០៣-១២-២០០២ បានប្ដឹងមិនសុខចិត្តនឹង សេចក្ដីសម្រេចទាំងមូល ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ២២៤(ឈ) ចុះថ្ងៃទី២៦-១២-២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី០៤-១២-២០០២ របស់ឈ្មោះម៉ី សារ៉ាត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី០៣-១២-២០០២ របស់ឈ្មោះឡុក គីម ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

៣-តម្កល់ដីកាសម្រេចពាក្យសុំលេខ២២(ឈ) ចុះថ្ងៃទី២៥-១១-២០០២ ទុកជាបានការ ។

៤ -បង្គាប់ឱ្យឈ្មោះម៉ី សារ៉ាត និងឈ្មោះនង កាណារិទ្ធិ បង់ប្រាក់ប្រដាប់ក្ដីចំនួន៤.០០០៛ ប្រាក់នេះត្រូវកាត់យកពីដើមបណ្ដឹងទាស់ ដែលបានបង់ទុករួចជាស្រេច ។

៥ - ដីកាសម្រេចនេះ ជំនុំជំរះ ជាសាធារណៈចំពោះមុខដើមបណ្ដឹងទាស់ឈ្មោះម៉ី សារ៉ាត និងឈ្មោះ នង កាណារិទ្ធិ និងចុងបណ្ដឹងទាស់ឈ្មោះស៊ឹម សៀប៉ាវ សម្រេចបើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

៦-ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ ទោះបីមានបណ្ដឹងឧទ្ធរណ៍ក៏ដោយ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ០១ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះម៉ី ណារ៉ាត និងបណ្ដឹងឧទ្ធរណ៍លេខ០៤ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះនង កាណារិទ្ធិ បានប្ដឹងមិនសុខចិត្តនឹង ដីកាសម្រេចកិច្ចការប្រញាប់ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥១(ក) ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទ១០-០២-២០០៣ របស់ឈ្មោះម៉ី ណារ៉ាត ទុកជាត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១២-០២-២០០៣ របស់ឈ្មោះនង កាណារិទ្ធិ ទុកជាត្រឹមត្រូវ តាមទម្រង់ និង គតិច្បាប់ ។

៣-បដិសេធដីកាកិច្ចកាប្រញាប់លេខ២៤ (ឈ) ចុះថ្ងៃទី២៦-១២-២០០២ របស់តុលាការក្រុងភ្នំពេញចោលជាសារបង់ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង២.៥៥០៛ រង្វាន់ក្រឡាបញ្ជី ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង អាជ្ញាធរតុលាការ៥០០០៛ សរុប១៣០០០៛ ។

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់។

បានឃើញបណ្ដឹងសាទុក្ខលេខ២៩៧ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះសសប បានប្ដឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញ សារណារបស់ឈ្មោះសសប ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ ។

បានឃើញ សារណាឆ្លើយតបរបស់ឈ្មោះម៉ី ណារ៉ាត ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ ។

បានឃើញសារណាឆ្លើយតបរបស់ឈ្មោះនង កាណារិទ្ធិ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ បណ្ដឹងសាទុក្ខរបស់ចុងចម្លើយស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

សាលដីការបស់ សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះមាលក្ខណៈខុសឆ្គងផ្នែកគតិច្បាប់ ។

អាស្រ័យហេតុនេះសូម ក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសម្រេច ។

លោកសសប បានឆ្លើយថា៖ ដោយសារអ្នកទាំងពីរនេះពេលមានរឿងប្ដឹងគ្នាគេបានលាក់ កំបាំងស្ងាត់ៗអត់ឱ្យខ្លួនបានដឹងហើយ ពេលនុវត្តវាបានប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួនយ៉ាងខ្លាំងដូច្នេះសូមឯឧកត្តមមេត្តា សម្រេចតាមច្បាប់ ទុកឱ្យតុលាការសម្រេចដល់រឿងអង្គសេចក្ដីចប់ជាស្ថាពរសិន ។

លោកមណរបានឆ្លើយថា៖តាមពិតលោកសសប បានធ្វើដោយរំលោភប៉ះពាល់ដល់សាលដីការបស់ តុលាការកំពូល ដែលបានចូលជាស្ថាពររួចហើយៗ គាត់មិនដែលមានបញ្ហាជាមួយរឿងក្ដីនេះទេ ព្រោះគាត់រស់នៅជាន់ទី២ ហើយគាត់បានចូលមកផ្ដិតមេដៃធ្វើជាសាក្សីក្នុងរឿងក្ដីនេះដែរ រួចពេលនោះគាត់មិនធ្វើ ជាតតិយជនតាំងពីពេលនោះ

មកទៅ នៅរឿងនេះបានចប់ជាស្ថាពរហើយ និងខ្លួនបានធ្វើប័ណ្ណកម្មសិទ្ធិរួចតាមច្បាប់ ត្រឹមត្រូវដែរ ។ ស្ថានភាពផ្ទះនេះមានសភាពទ្រុឌទ្រមណាស់ ពុកផុយមានលិចទឹកហូរចូលមកដល់ក្នុងផ្ទះរបស់ខ្លួនដោយរឿងនេះចេះតែអូសបន្លាយហូរពេកជាហេតុនាំឱ្យខ្លួនមិនបានជួសជុលផ្ទះអ្វីទាំងអស់ ដោយសារតែគាត់ប្តឹងជំទាស់នឹងសាលដីការបស់តុលាការកំពូលបណ្តាលឱ្យប៉ះពាល់ប្រយោជន៍របស់ខ្លួនយ៉ាងខ្លាំង ។ ពិសេសខ្លួនបានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិកាន់កាប់អចលនវត្ថុដែលមានលេខ០៣៧៤៥/១៨-១០-២០០២ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ក្រុងភ្នំពេញ។ តាមមាត្រា៣០.៣១, ៣៥ និង ៣៧ នៃច្បាប់ភូមិបាលយើងខ្ញុំទាំងអស់គ្នាមានសិទ្ធិគ្រប់គ្រាន់ក្នុងការកាន់កាប់ដីឡូត៍នេះដោយពេញលេញ ។

**<u>សំណូមពរៈ</u>**

-សុំបដិសេធដីកាសម្រេចកិច្ចការប្រញាប់របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

-សុំតម្កល់សាលដីការបស់ សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

លោកនង កាណារិទ្ធិ បានឆ្លើយថាៈ ខ្លួនជាអ្នកតំណាងឱ្យអ្នកស្រីឡុក គីម ខ្លួនសុំឯកភាពលើការបកស្រាយរបស់លោកម៉ី ណារ៉ាត ទាំងស្រុង ។ ដីកាសម្រេចកិច្ចការប្រញាប់របស់តុលាការក្រុងភ្នំពេញបានសម្រេចធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងនឹងសាលដីការបស់តុលាការកំពូល និងតាមកំណត់ហេតុចុះអនុវត្តសាលដីការបស់គណៈកម្មការចំរុះដែលបានធ្វើចប់សព្វគ្រប់ ព្រមទាំងបានបែងចែកដីឡូត៍តាមនីតិវិធីដែរ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៩៧ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះសសប ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះ បានពាមមាត្រា១៤ នៃច្បាប់ ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយសំអាងទៅលើសាលដីកាកំពូលលេខ១១៣ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០២ និងថាសាលដីកានេះត្រូវបានអនុវត្តរួចរាល់ហើយនោះ គឺជាការភ័ន្តច្រឡំពីព្រោះ ថាសាលដីការបស់តុលាការកំពូល ដែលត្រូវបានយកទៅអនុវត្តនោះ គឺសាលដីកាលេខ៧៨ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ និងសាលាដីកាលេខ១១៨ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០២ ពេលចុះទៅអនុវត្តសសាលដីកានេះ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០២ និងថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០២ ពេលចុះទៅអនុវត្តមានការតវ៉ាលើសំណាក់ក្រុមគ្រួសាររបស់លោកសសប ។ ម្យ៉ាងវិញទៀត សាលដីកានេះមានអានុភាពចំពោះតែអ្នកស្រី ឡុក គឹម និងហេង ពន្លកតែប៉ុណ្ណោះទេ គឺពុំមានអានុភាពចំពោះលោកសសប ឡើយ ។

-យល់ឃើញថារឿងអង្គសេចក្តីរវាងដើមចោទ គឺលោកសសប និងចុងចម្លើយគឺអ្នកស្រីឡុក គឹម និង ហេង ពន្លក ត្រូវបានតុលាការថ្នាក់ក្រោមកំពុងចាត់ការ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៥១(ក) ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខតួក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ២៩៧ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ របស់លោកសសប ទុកត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៥១(ក) ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំមូលដោយឥតបង្វិល ។

៣-ហាមឃាត់ឈ្មោះហេង ពន្លក និងឈ្មោះឡុក គីម មិនឱ្យលក់ដូរ ជួល បញ្ចាំ ធ្វើអំណោយ និងសាងសង់សំណង់នៅលើដីឡូត៍លេខ១២២ ផ្លូវ២៦១ ក្រុម៣០ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ជាបណ្តោះអាសន្នរង់ចាំតុលាការសម្រេចដល់អង្គសេចក្តីជាស្ថាពរ ។

៤-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ១១ប្រ ចុះបញ្ចូលក្នុងសំណុំរឿងអង្គសេចក្តីនៅតុលាការក្រុងភ្នំពេញ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកនកណារ បានបង់នៅតុលាការកំពូល គឺ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៦-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ ។